សុន្ទរកថារបស់ **ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ

**០៩ មីនា ២០១៧**

- សូមគោរព **លោក ពឹង ទ្រីដា** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ
- សូមគោរព **លោក ថៃ ឡូ** នាយកប្រតិបត្តិទឹកស្អាត១០០១
- សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ សម្រាប់គម្រោងKUSANONE។

គម្រោងជំនួយទី១ ដែលមានថវិកាចំនួន៨២,៩៦០ដុល្លារអាមេរិក សម្រាប់គម្រោងពង្រឹងសហគមន៍កសិកម្មក្នុងស្រុកត្បែងមានជ័យ និងស្រុកគូលែន ខេត្តព្រះវិហារ។ គម្រោងនេះ នឹងផ្តល់ជូននូវម៉ាស៊ីនច្រូតស្រូវចំនួន២គ្រឿង និងអគារមជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន២ ដល់សហគមន៍កសិកម្មទាំង២។ គម្រោងនេះត្រូវបានរំពឹងថា នឹងលើកកម្ពស់គុណភាពអង្ករសរីរាង្គសម្រាប់នាំចេញ និងធ្វើអោយជីវភាពរស់នៅរបស់កសិករប្រមាណជា ៤៦០នាក់កាន់តែល្អប្រសើរ។

គម្រោងជំនួយទី២ ដែលមានថវិកាចំនួន៧៧,៨៤០ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់ស្ថានីយផលិតទឹកស្អាតខ្នាតតូច ក្នុងឃុំចំនួន៦ នៃខេត្តតាកែវ។ គម្រោងនេះ នឹងផ្តល់ជូនស្ថានីយផលិតទឹកស្អាតខ្នាតតូចចំនួន៦ និងម៉ាស៊ីនចាំបាច់សម្រាប់ផលិតទឹកស្អាតជាដើម។ គម្រោងនេះត្រូវបានរំពឹងថា នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណជា ១,៩០០គ្រួសារនៅក្នុងតំបន់។ ខ្ញុំសង្ឃឹមថាគម្រោងនេះ នឹងធានាបាននូវទឹកស្អាតប្រកបដោយសុវត្ថិភាព និងស្មើភាពសម្រាប់ប្រជាជន និងរួមចំណែកក្នុងការកាត់បន្ថយជម្ងឺដែលឆ្លងតាមទឹកមិនស្អាត។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាគម្រោងទាំងនេះ នឹងត្រូវបានអនុវត្តយ៉ាងរលូន ហើយសំណង់និងសម្ភារៈបរិក្ខារទាំងអស់ដែលបានផ្តល់ជូនតាមរយៈគម្រោងទាំងនេះ នឹងត្រូវបានថែទាំអោយបានល្អ ដើម្បីអោយប្រជាជនអាចប្រើប្រាស់បានយូរអង្វែង និងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកាន់តែច្រើនថែមទៀត។ ខ្ញុំក៏សង្ឃឹមថា គម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**